VP.Start

# ដំណោះស្រាយវៃឆ្លាត

## ការធ្វើទំនើបកម្មឌីជីថល លើបណ្ដាញចែកចាយថាមពលអគ្គិសនី

DRCs ...

UNIQUE

# DRC-003




info@vpstart.com / sale@vpstart.com | www.vpstart.com | 023 888 167

VP-DOC-S.CTL-DRC-003.KH-V1.0



# DRC-003

## ឧបករណ៍វៃឆ្លាត សម្រាប់ធ្វើទំនើបកម្មលើ Cooper Auto Recloser (ACR)



Eaton V2




## លក្ខណៈពិសេស

- បញ្ជាផ្តាច់-ភ្ជាប់ Switchgear របស់ ACR ពីចម្ងាយ
- ទទួលបានព័ត៌មានភ្លាមៗពេលមានកំហូចកើតឡើងនៅលើបណ្តាញ ឬមានភាពមិនប្រក្រតីផ្សេងៗនៅលើ ACR
- អាចត្រួតពិនិត្យមើលស្ថានភាពរបស់ ACR គ្រប់ពេលវេលា គ្រប់ទីកន្លែង



## តើ DRC-003 មានលក្ខណៈពិសេសបែបណាខ្លះក្នុងការគ្រប់គ្រងបណ្តាញចែកចាយថាមពលអគ្គិសនី ?



DRC-003 ជាឧបករណ៍វៃឆ្លាត ដែលត្រូវបានអភិវឌ្ឍឡើងដើម្បីធ្វើទំនើបកម្មលើ COOPER Auto Circuit Recloser នៅលើបណ្តាញចែកចាយថាមពលអគ្គិសនីតង់ស្យុងមធ្យម 22kV & 35kV។ DRC-003 ផ្លាស់ប្តូរការគ្រប់គ្រង COOPER Auto Circuit Recloser ពីមុន ទៅជាការគ្រប់គ្រងតាមបែបឌីជីថល ដែលកាត់បន្ថយការចំណាយធនធានក្នុងការចុះទៅធ្វើប្រតិបត្តិការដោយផ្ទាល់ ជួយពង្រឹងគុណភាពថាមពល និងជួយឱ្យការគ្រប់គ្រងមានប្រសិទ្ធភាពខ្ពស់។

DRC-003 មានសមត្ថភាពបញ្ជូនព័ត៌មានពី Controller របស់ COOPER Auto Circuit Recloser ទៅកាន់បន្ទប់បញ្ជា ឬទៅកាន់ទូរសព្ទដៃស្មាតហ្វូនរបស់ប្រតិបត្តិករមានដូចជា ព័ត៌មានទូទៅអំពីស្ថានភាពរបស់បណ្តាញ ព័ត៌មានអំពីកំហូច ឬភាពអសកម្មនានា និងលទ្ធភាពក្នុងការបញ្ជាផ្តាច់ ឬភ្ជាប់ Switchgear របស់ ACR ពីចម្ងាយបានយ៉ាងឆាប់រហ័ស និងមានប្រសិទ្ធភាព។




▲ ការដំឡើងមានភាពរហ័ស និងងាយស្រួល




▲ DRC-003 ដែលដំឡើងរួច

# បង្ហាញទិន្នន័យ REAL-TIME




## មុខងារផែនទី (Map View)




## តើ DRC-003 មានមុខងារពិសេសៗបែបណាខ្លះ ?

### ការទទួលបានទិន្នន័យ Real-Time (Real-Time Data Monitoring)

ក្រុមការងារអគ្គិសនីអាចត្រួតពិនិត្យ និងទាញយកទិន្នន័យ Real-time ពី COOPER Auto Recloser ដោយមិនចាំបាច់ត្រូវចុះទៅដល់ទីតាំងដោយផ្ទាល់ដូចមុនទៀតនោះទេ។ តាមរយៈទិន្នន័យទាំងអស់នោះ បានផ្តល់លទ្ធភាពគ្រប់គ្រាន់ដល់ក្រុមការងារប្រើប្រាស់ក្នុងការដោះស្រាយបញ្ហានានាបានយ៉ាងឆាប់រហ័ស និងមានប្រសិទ្ធភាពខ្ពស់។

### ផ្តល់ព័ត៌មានអំពីកំហូច (Fault Detection)

DRC-003 ផ្តល់ព័ត៌មានភ្លាមៗ ពេលដែលមានកំហូចកើតឡើង ដែលផ្តល់ភាពងាយស្រួលដល់ក្រុមការងារចាត់វិធានការដោះស្រាយបានទាន់ពេលវេលា។

## ប្រភេទ ALARM របស់ DRC-003



Switchgear Off



MV Absence



Communication Maintenance

### ផ្តល់ព័ត៌មានអំពីភាពអសកម្មនានានៅលើ Controller របស់ COOPER Auto Recloser (Abnormal Detection)

VP.Start បានបន្ថែមមុខងារពិសេសមួយទៀត ដើម្បីផ្តល់ព័ត៌មានអំពីបញ្ហាផ្សេងៗនៅលើ Controller របស់ Auto Recloser ដូចជា៖ MCB Switch Off, Switchgear Maintenance, Door Open Alarm, និង Battery Low, ជាដើម។ មុខងារនេះ អាចឱ្យក្រុមការងារជំនាញដឹងមុនអំពីភាពអសកម្មនានានៅលើបរិក្ខារអគ្គិសនី Auto Recloser ដើម្បីអាចរៀបចំដោះស្រាយបញ្ហាទាំងអស់នោះបានទាន់ពេលវេលា។

## ALARMS ពេលមានភាពអសកម្មកើតឡើង



Door Open Alarm



Battery Low



MCB Switch Off

## បញ្ជាផ្ដាច់-ភ្ជាប់ Switchgear ពីចម្ងាយ ( Remote Control )

DRC-003 មានសមត្ថភាពបញ្ជាផ្ដាច់-ភ្ជាប់ Switchgear របស់ Auto Recloser ពីចម្ងាយគ្រប់ពេលវេលា និងគ្រប់ទីកន្លែង ដោយគ្រាន់តែប្រើប្រាស់ទូរសព្ទដៃស្មាតហ្វូន (PLUM) ឬជាមួយប្រព័ន្ធ RPM Grid។ មុខងារពិសេសនេះ ជួយកាត់បន្ថយការចំណាយថ្លៃចុះប្រតិបត្តិការ និងជួយការពារសុវត្ថិភាពដល់ក្រុមការងារពីការធ្វើប្រតិបត្តិការដោយផ្ទាល់ផងដែរ។

## ទិន្នន័យ Measurements

តាមរយៈ DRC-003 ក្រុមការងារអាចពិនិត្យមើលទិន្នន័យសំខាន់ៗនៅលើ Auto Recloser ដូចជាទិន្នន័យចរន្ត (Current) តង់ស្យុង (Voltage) អានុភាពសកម្ម (Active Power) អានុភាពអសកម្ម (Reactive Power) កត្តាអានុភាព (Power Factor) និងប្រេកង់ (Frequency) ជាដើម។

## ការកំណត់ Settings

ឥឡូវនេះ ក្រុមការងារបច្ចេកទេសអាចកំណត់ Settings សំខាន់ៗនៅលើ COOPER Auto Circuit Controller ដោយគ្រាន់តែប្រើប្រាស់កម្មវិធី PLUM ឬ RPM Grid ជាការស្រេច។

## គំនូរប្លង់បច្ចេកទេស (Single Diagram)

តាមរយៈប្រព័ន្ធគ្រប់គ្រង RPM Grid ក្រុមការងារអាចពិនិត្យមើលពីស្ថានភាពរបស់ DRC-003 ភ្លាមៗ និងផ្ដល់ភាពងាយស្រួលក្នុងការកំណត់សម្គាល់ទីតាំងដែលមានកំហូចផ្សេងៗជាដើម។

## មុខងារផែនទី (Map View)

ក្រុមការងារអាចមើលទីតាំងរបស់ DRC-003 ដែលបានភ្ជាប់ជាមួយ Auto Recloser បានភ្លាមៗ នៅលើផែនទី Google ផ្ដល់ភាពងាយស្រួលក្នុងការកំណត់ទីតាំងបញ្ហាពេលមានកំហូច ឬភាពអសកម្មនានា ដែលកើតឡើងនៅលើបណ្ដាញអគ្គិសនី។

# ដើម្បីគ្រប់គ្រង DRC-003 បានតើត្រូវធ្វើដូចម្ដេច?

### លោកអ្នកអាចគ្រប់គ្រង DRC-003 ដូចខាងក្រោម៖

- ការគ្រប់គ្រងតាមប្រព័ន្ធទូរសព្ទដៃ ដោយប្រើប្រាស់កម្មវិធី PLUM
- ការគ្រប់គ្រងតាមប្រព័ន្ធ RPM Grid នៅក្នុងបន្ទប់បញ្ជា
- បញ្ជាផ្ដាច់-ភ្ជាប់ ឬស្ដាប់ពីស្ថានភាពបណ្ដាញតាមរយៈមុខងារ Call Control។






# តើ DRC-003 ផ្ដល់ផលចំណេញដល់អាជីវកម្មចែកចាយថាមពលអគ្គិសនីបែបណាខ្លះ?

## ការធ្វើទំនើបកម្មដោយរក្សាបរិក្ខារអគ្គិសនីដែលកំពុងតែប្រើប្រាស់ឱ្យនៅដដែល

គ្រាន់តែភ្ជាប់ DRC-003 ជាមួយ COOPER Auto Circuit Recloser គឺអាចធ្វើទំនើបកម្មបានភ្លាមៗ។ បច្ចេកវិទ្យាបែបថ្មីនេះ មិនត្រឹមតែធ្វើបរិក្ខារ Auto Recloser វ៉ៃឆ្លាត និងជួយឱ្យការគ្រប់គ្រងបណ្ដាញមានប្រសិទ្ធភាពប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបានផ្ដល់លទ្ធភាពគ្រប់គ្រាន់ក្នុងការធ្វើទំនើបកម្មដោយចំណាយទុនវិនិយោគតិចបំផុត បើប្រៀបធៀបទៅនឹងការផ្លាស់ប្ដូរថ្មីទាំងស្រុង។

## ការធ្វើទំនើបកម្មរហ័ស

ជាមួយ DRC-003 ការធ្វើទំនើបកម្មចំណាយពេលប្រហែលត្រឹម 30 នាទីប៉ុណ្ណោះ គឺអាចធ្វើឱ្យ Auto Recloser ពីធម្មតាទៅជាវ៉ៃឆ្លាតភ្លាមៗ។

## ងាយស្រួលគ្រប់គ្រង

VP.Start បានបង្កើតប្រព័ន្ធគ្រប់គ្រងដែលផ្ដល់លទ្ធភាពដល់អ្នកប្រើប្រាស់គ្រប់កម្រិតទាំងអស់។ ក្រុមការងារអគ្គិសនីគ្រាន់តែចុចពីរ ទៅបីឃ្លីក គឺអាចទទួលបានព័ត៌មានពីបណ្ដាញចែកចាយ ឬបញ្ជាផ្ដាច់-ភ្ជាប់ Switchgear Auto Recloser បានភ្លាមៗតែម្ដង។





## ផ្តល់ផលចំណេញត្រឡប់មកវិញលឿន (Rapid Return on Investment)

- ការទទួលបានព័ត៌មានអំពីបញ្ហាផ្សេងៗនៅលើបណ្តាញចែកចាយរហ័សឈានទៅរកការកាត់បន្ថយទំហំ និងរយៈពេលនៃការដាច់ចរន្តអគ្គិសនីមកនៅសល់តូច។

- ការទទួលបានទិន្នន័យពី Auto Recloser ដែលអាចដឹងពីការលេចជ្រាបចរន្ត ភាពមិនស្មើគ្នានៃចរន្តតាមហ្វានីមួយៗ ការធ្លាក់ចុះនៃតង់ស្យុង និងទិន្នន័យសំខាន់ៗផ្សេងៗជាច្រើនទៀត ដែលផ្តល់លទ្ធភាពក្នុងការវិភាគ និងបង្កើតការសម្រេចចិត្តបានលឿនទាំងការដោះស្រាយបញ្ហា និងការបន្ថែមអតិថិជនថ្មី ឬការសម្រេចចិត្តក្នុងការពង្រីកអាជីវកម្មចែកចាយបន្ថែមទៀតផងដែរ។

- ការបញ្ជាផ្តាច់ ឬភ្ជាប់ចរន្តអគ្គិសនីពីចម្ងាយដែលបានកាត់បន្ថយការចំណាយថ្លៃប្រតិបត្តិការចុះទៅដោយផ្ទាល់។

ទាំងអស់នេះ មិនត្រឹមតែជួយឱ្យបណ្តាញចែកចាយមានភាពរឹងមាំ និងមានស្ថិរភាពប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងផ្តល់ផលចំណេញត្រឡប់មកវិញលឿនដល់អាជីវកម្មចែកចាយថាមពលអគ្គិសនីផងដែរ។

## ដំណើរការរបស់ប្រព័ន្ធ (System Architecture)



VP.Start

**VP.Start HQ**
Address: #15, Street 604, Sangkat Boeung Kok 2, Khan Toul Kork, Phnom Penh, Cambodia.

**VP.Start Sen Sok Valley Campus**
Address: #29, Street 1946, Sangkat Phnom Penh Thmey, Khan Sen Sok, Phnom Penh, Cambodia.

VP.Start

www.vpstart.com